

# ព្រះយេស៊ូវគ្រីស្ទគឺជា . . .

ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល

អង្គបង្កបង្កើត

# ព្រះអង្គសង្គ្រោះ

កូនចៀមនៃព្រះ

# ព្រះរាជបុត្រានៃព្រះ

## ព្រះរាជបុត្រាបង្កើតតែមួយ

ព្រះដ៏ប្រោសលោះ

# ព្រះមែស៊ី

អ្នកគង្វាលល្អ

« មើលចុះ ផ្លូវសម្រាប់មនុស្ស គឺចង្អៀត ប៉ុន្តែសន្ធឹងត្រង់នៅចំពោះមុខគេ ហើយអ្នកឆ្មាំទ្វារ គឺជា**ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល** ហើយទ្រង់មិនជួលបាវបម្រើនៅទីនោះឡើយ » ( នីហ្វៃទី២ ៩:៤១ ) ។

« ទ្រង់នឹងត្រូវបានហៅថា ព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រានៃព្រះ ព្រះវរបិតានៃស្ថានសួគ៌ និងផែនដី **ព្រះដែលបង្កើតវត្ថុ**សព្វសារពើចាប់តាំងពីដំបូងមក » ( ម៉ូសាយ ៣:៨ ) ។

« បើសិនជាអ្នករាល់គ្នាជឿដល់ព្រះគ្រីស្ទយ៉ាងនោះមែន ហើយបានទទួលបុណ្យជ្រមុជ ដំបូងដោយទឹក ហើយបន្ទាប់មក ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ គឺធ្វើតាមគំរូនៃ**ព្រះអង្គសង្គ្រោះ**របស់យើង . . . នោះនឹងបានស្រួលដល់អ្នករាល់គ្នាហើយនៅក្នុងថ្ងៃជំនុំជំរះ » ( មរមន ៧:១០ ) ។

« **កូនចៀមនៃព្រះ** គឺជាព្រះរាជបុត្រានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ហើយគឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ហើយ . . . មនុស្សទាំងអស់ត្រូវតែមករកព្រះអង្គ បើពុំនោះសោតទេពួកគេនឹងពុំបានសង្គ្រោះឡើយ » ( នីហ្វៃទី១ ១៣:៤០ ) ។

« ហើយពីព្រោះទ្រង់គង់នៅក្នុងសាច់ឈាម នោះទ្រង់នឹងត្រូវឲ្យព្រះនាមថា ជា**ព្រះរាជបុត្រានៃព្រះ** » ( ម៉ូសាយ ១៥:២ ) ។

« អស់អ្នកណាដែលប្រែចិត្ត ហើយពុំមានធ្វើចិត្តរឹងរូសទេ នោះនឹងបានទទួលសេចក្ដីមេត្តាករុណា តាមរយៈ**ព្រះរាជបុត្រាបង្កើតតែមួយ**របស់យើង ចំពោះការផ្ដាច់បាប » ( អាលម៉ា ១២:៣៤ ) ។

« ឪពុកដឹងថា កូនត្រូវបានប្រោសលោះឲ្យរួច ពីព្រោះតែសេចក្ដីសុចរិតនៃ**ព្រះដ៏ប្រោសលោះ**របស់កូន ត្បិតកូនបានឃើញថា ដល់កាលដ៏ពេញកំណត់ នោះទ្រង់នឹងយាងមកប្រទានសេចក្ដីសង្គ្រោះដល់មនុស្សលោក » ( នីហ្វៃទី២ ២:៣ ) ។

« [ លីហៃ ] បានធ្វើបន្ទាល់ថា អ្វីៗដែលលោកបានឃើញ ហើយបានឮ ព្រមទាំងអ្វីៗដែលលោកបានអានក្នុងគម្ពីរផងនោះ បានសម្ដែងយ៉ាងច្បាស់ប្រាប់ អំពីការយាងមកនៃ**ព្រះមែស៊ី** » ( នីហ្វៃទី១ ១:១៩ ) ។

« **អ្នកគង្វាលល្អ**នឹងស្រែកហៅអ្នក មែនហើយ គឺដោយនូវឈ្មោះរបស់លោកផ្ទាល់ដែលលោកនឹងហៅអ្នក គឺជាព្រះនាមនៃព្រះគ្រីស្ទ » ( អាលម៉ា ៥:៣៨ ) ។

រូបភាពខាងលើ អ្នកគង្វាលល្អ ដោយ ដេល ផាសុន រូបភាពខាងក្រោយ ព្រះគ្រីស្ទ ដោយ ហេនរិច ហូហ្វម៉ាន់